ក្រសួង រ.ដ.ន.ស.
ចូល
លេខ 4620
ចុះថ្ងៃ 9.12.21
ម៉ោង ...

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៣៣២១...សជណ

ថ្ងៃពុធ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
- **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**
- **ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យនិងចាត់វិធានការបង្រ្កាបការទន្រ្ទានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៃតំបន់បឹងទន្លេសាបស្ថិតក្នុងភូមិសាស្ត្រខេត្តសៀមរាប។

**យោង ៖**
- លិខិតលេខ២៧៥៨ ដនស/អសដក ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ៤៥៩ ខន/០២១ សជណ ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការចំពោះមុខដូចខាងក្រោម៖

១- បង្គោលដែនព្រៃលិចទឹកដែលមិនទាន់បានបោះ និងខូច ត្រូវបោះបំពេញបន្ថែមឱ្យបានគ្រប់ឡើងវិញ ដោយប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹកនិងឧតុនិយម។

២- ប្រគល់ភារកិច្ចជូនក្រសួងធនធានទឹកនិងឧតុនិយម រៀបចំប៉ាណូបង្ហាញទីតាំងដែនព្រៃលិចទឹកដែលបានកំណត់។

៣- អាជ្ញាធរទន្លេសាបតាមរយៈក្រសួងធនធានទឹកនិងឧតុនិយម ជាអ្នកស្នើសុំចុះបញ្ជីដីរដ្ឋ។

៤- ជូនរដ្ឋបាលខេត្តសៀមរាបចេញលិខិតណែនាំដល់អាជ្ញាធរស្រុក ឃុំ បញ្ឈប់រាល់ចរន្តការសុំកាន់កាប់ដី ផ្ទេរសិទ្ធិកាន់កាប់ដី ឬជួលដីរដ្ឋក្នុងដែនព្រៃលិចទឹកព្រមទាំងចេញលិខិតបដិសេធលើរាល់លិខិតដែលបានចេញរួចពីពេលមុន។

៥- ជូនរដ្ឋបាលខេត្តសៀមរាបចាត់វិធានការបញ្ឈប់ការចូលទន្ទ្រានដីក្នុងដែនព្រៃលិចទឹកបន្តទៀត ធ្វើអត្តសញ្ញាណអ្នកដែលបានចូលទន្ទ្រាន និងដំឡើងផែនទី ដើម្បីធ្វើការដកហូតដីនិងចាត់វិធានការតាមផ្លូវច្បាប់ ដោយត្រូវកសាងអង្គហេតុ និងដាក់បណ្ដឹងអាជ្ញាទៅតុលាការ។

៦-រាល់កិច្ចប្រជុំបូកសរុបការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ រដ្ឋបាលខេត្តត្រូវរាយការណ៍វឌ្ឍនភាពនៃការគ្រប់គ្រង និងការចាត់វិធានការការពារដីព្រៃលិចទឹក។

៧- ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តសៀមរាប ត្រូវជួយជំរុញការអនុវត្តនីតិវិធីចំពោះសំណុំរឿងបទល្មើសទន្ទ្រានព្រៃលិចទឹកក្រោយពេលទទួលបានបណ្ដឹង។

៨- ទន្ទឹមនឹងវិធានការផ្លូវច្បាប់ ជនល្មើសត្រូវដាំដើមឈើឡើងវិញលើផ្ទៃដីដែលបានទន្ទ្រាន។ ការដាំដើមឈើឡើងវិញ ផ្តល់អាទិភាពលើការដាំដើមឫស្សី។

៩- ចំពោះប្រជាពលរដ្ឋដែលបានដាំដំណាំ ពិសេសដំណាំស្រូវ ទុកពេលឱ្យប្រមូលផល រួចត្រូវធ្វើលិខិតទទួលកំហុស និងប្រគល់ដីព្រៃលិចទឹកជូនរដ្ឋវិញ។

១០-រកមុខសញ្ញានិងជូនដំណឹងដល់អ្នកដែលមានធនធានជួលប្រជាពលរដ្ឋចូលកាប់រានដីក្នុងដែនព្រៃលិចទឹក និងមន្ត្រីរាជការស៊ីវិល ក៏ដូចជាកងកម្លាំងដែលបានប្រព្រឹត្តល្មើសចូលទន្ទ្រានដីព្រៃលិចទឹក ឱ្យចេញមុខសារភាពនិងប្រគល់ដីជូនរដ្ឋវិញ ដើម្បីទទួលបានការសម្រាលទោសទណ្ឌ។ ចំពោះបុគ្គល ឬអង្គភាពមានសមត្ថកិច្ចដែលដឹងអំពីមុខសញ្ញាប្រព្រឹត្តបទល្មើសហើយមិនរាយការណ៍ ត្រូវទទួលខុសត្រូវដោយខ្លួនឯងចំពោះមុខច្បាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឈួន សុធី**

**ចម្លងជូនៈ**

- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អាជ្ញាធរទន្លេសាប
- ឯកសារ កាលប្បវត្តិ